CAO
COMPLIANCE ADVISOR OMBUDSMAN

# របាយការណ៍ស្ដីពីការប៉ាន់ប្រមាណរបស់ការិយាល័យ CAO

# ពាក្យបណ្ដឹងទាក់ទងទៅនឹងគម្រោងអាកាសយានដ្ឋានកម្ពុជារបស់ IFC (២១៣៦៣)

## ភ្នំពេញ ប្រទេសកម្ពុជា

*ខែមករា ឆ្នាំ២០១៤*

*ការិយាល័យប្រតិបត្តិ ទីប្រឹក្សា អ្នកដោះស្រាយវិវាទ*

*សម្រាប់*

*សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ/ទីភ្នាក់ងារធានាការវិនិយោគពហុភាគី*

www.cao-ombudsman.org

## អំពីការិយាល័យ CAO

ការិយាល័យប្រតិបត្តិ ទីប្រឹក្សា អ្នកដោះស្រាយវិវាទ (ការិយាល័យ CAO) គឺជាយន្តការគណនេយ្យភាពឯករាជ្យ សម្រាប់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសាខាផ្នែក វិស័យឯកជនរបស់ក្រុមធនាគារពិភពលោក។ ការិយាល័យ CAO រាយការណ៍ដោយផ្ទាល់ជូនដល់ប្រធានក្រុមធនាគារពិភពលោក ហើយការិយាល័យនេះ មានអាណត្តិការងារក្នុងការជួយដោះស្រាយពាក្យបណ្តឹងពីប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ពីគម្រោងដែលមានការគាំទ្រពី IFC/MIGA ក្នុងលក្ខណៈមួយប្រកបដោយភាពយុត្តិធម៌ មិនលំអៀង និងប្រកបដោយភាពស្ថាបនា សំដៅលើកកម្ពស់លទ្ធផលផ្នែកសង្គម និងបរិស្ថាននៃគម្រោងទាំងនោះ។

សម្រាប់ព័ត៌មានបន្ថែម សូមមើល www.cao-ombudsman.org។

## តារាងមាតិកា

**១. ទិដ្ឋភាពទូទៅ** ..... ៥

**២. សាវតា** ..... ៥

២.១. គម្រោង ..... ៥

២.២. ពាក្យបណ្តឹង ..... ៦

**៣. សង្ខេបការប៉ាន់ប្រមាណ** ..... ៨

៣.១ វិធីសាស្ត្រ ..... ៨

៣.២. ការរកឃើញ ..... ៨

៣.២.១. សង្ខេបបញ្ហា ..... ៨

៣.២.២. សង្ខេបអំពីគោលដៅ និងប្រយោជន៍របស់អ្នកពាក់ព័ន្ធ ..... ៩

**៤. ជំហានបន្ទាប់** ..... ១០

## បញ្ជីរាយនាមអក្សរកាត់

| | |
|---|---|
| CAO | ការិយាល័យប្រតិបត្តិ ទីប្រឹក្សា អ្នកដោះស្រាយវិវាទ |
| EC | សមធម៌កម្ពុជា |
| ICAO | អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ |
| IFC | សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ |
| LC | គណៈកម្មាធិការដីធ្លី |
| MIGA | ទីភ្នាក់ងារធានាការវិនិយោគពហុភាគី |
| PPIA | អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ |

## ១. ទិដ្ឋភាពទូទៅ

ក្នុងខែមិថុនា ឆ្នាំ២០១៣ ការិយាល័យ CAO បានទទួលពាក្យបណ្តឹងមួយពីគ្រួសារចំនួន៥៩ ដែលរស់នៅក្នុង ភូមិថ្មគោល និងភូមិព្រៃជីសាក់ ("ដើមបណ្តឹង") ដោយមានកិច្ចគាំទ្រ និងជំនួយពីអង្គការសមធមិកម្ពុជា (EC) ដែលជាអង្គការមិនមែនរដ្ឋាភិបាលកម្ពុជាមួយ។ ពាក្យបណ្តឹងបានលើកឡើងនូវបញ្ហាកង្វល់មួយចំនួនអំពីការគំរាមកំហែងយកដី និងលទ្ធភាព ដែលអាចនាំឱ្យមានការបង្ខំបណ្តេញប្រជាជនចេញ ទាក់ទងទៅនឹងការអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយក្រុមហ៊ុន Société Concessionnaire de l'Aéroport ("ក្រុមហ៊ុន")។ ការិយាល័យ CAO បានកំណត់ថាពាក្យបណ្តឹងនេះ មានល័ក្ខខ័ណ្ឌស្របទៅតាមលក្ខណៈវិនិច្ឆ័យសមស្របចំនួន៣ ដោយផ្អែកលើគោលការណ៍ណែនាំប្រតិបត្តិរបស់ខ្លួន និង បានចាប់ផ្តើមធ្វើការប៉ាន់ប្រមាណទៅលើពាក្យបណ្តឹង។ ក្នុងអំឡុងពេលនៃការប៉ាន់ប្រមាណ ដែលធ្វើឡើងដោយការិយាល័យ CAO អ្នកពាក់ព័ន្ធសំខាន់ៗ[១] បានឯកភាពចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទមួយតាមបែបសហការ។ របាយការណ៍ស្តីពីការប៉ាន់ប្រមាណនេះ ផ្តល់នូវទិដ្ឋភាពទូទៅមួយអំពីដំណើរការប៉ាន់ប្រមាណ រាប់បញ្ចូលការពណ៌នាអំពីគម្រោង ពាក្យបណ្តឹង វិធីសាស្រ្តប៉ាន់ប្រមាណ និងជំហានបន្ទាប់។

## ២. សាវតា

### ២.១. គម្រោង[២]

Société Concessionnaire de l'Aéroport ("SCA") ទទួលបានសម្បទានរយៈពេល២០ឆ្នាំ (ចាប់តាំងពីឆ្នាំ ១៩៩៥) ពីរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ("RGC") ដើម្បីរៀបចំ ផ្តល់ហិរញ្ញវត្ថុគាំទ្រ កសាង ថែរក្សា និងធ្វើប្រតិបត្តិការនៅក្នុងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ("PPIA") អាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ ("SRAIA") និងអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ (SIA) ក្នុងប្រទេសកម្ពុជា។ អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ស្ថិតនៅចម្ងាយ ១០គីឡូម៉ែត្រ ភាគខាងលិចនៃរាជធានីភ្នំពេញ និងជាច្រកចូលចម្បងមកកាន់ប្រទេសកម្ពុជា។

---

[១] សម្រាប់គោលបំណងនៃរបាយការណ៍នេះ "អ្នកពាក់ព័ន្ធ" សំដៅចំពោះដើមបណ្តឹងដែលបានដាក់ពាក្យទៅការិយាល័យ COA , រាជរដ្ឋាភិបាល កម្ពុជា , ក្រុមហ៊ុន SCA និងអង្គការសមធមិកម្ពុជា។ ប៉ុន្តែ ចំណុចនេះពុំបានហាមឃាត់អ្នកពាក់ព័ន្ធដទៃទៀតមិនឱ្យចូលរួមនៅក្នុងដំណើរការដោះស្រាយវិវាទរបស់ CAO ឡើយ ប្រសិនបើពួកគេត្រូវការដោះស្រាយបញ្ហានេះ។

[២] ឯកសារគម្រោងរបស់ IFC - ការត្រួតពិនិត្យឡើងវិញពីដំបូងទៅលើ PDS និងការសង្ខេបអំពីព័ត៌មានគម្រោង https://ifcndd.ifc.org/ifcext/spiwebsite1.nsf/78e3b305216fcdba85257a8b0075079d/ada895bf55cf98ff852576ba000e2572?opendocument (ចូលមើលព័ត៌មាន នៅថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ២០១៣)

កំណើនចរាចរណ៍នាពេលថ្មីៗនេះ នៅឯអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ បានបង្កើតឱ្យមាននូវសេចក្តីត្រូវការពង្រីកមូលដ្ឋានអាកាសយានដ្ឋានក្នុងកម្រិតមួយគួរឱ្យកត់សម្គាល់ ដើម្បី អនុញ្ញាតឱ្យអាកាសយានដ្ឋានអាចធ្វើប្រតិបត្តិការក្នុងបទដ្ឋានសុវត្ថិភាព និងប្រសិទ្ធភាពកម្រិតអន្តរជាតិ។ ការពង្រីក និងការធ្វើទំនើបកម្មនៃហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន ត្រូវបានគេមើលឃើញថាជាសកម្មភាពមួយដ៏សំខាន់ចំពោះ កិច្ចខិតខំរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការធ្វើឱ្យប្រទេសកម្ពុជាមានភាពរីកចម្រើនលើវិស័យទេសចរណ៍ ដែលការទាក់ទាញចម្បង គឺប្រាសាទអង្គរ។ ដូច្នេះ ស្ថិតក្រោមសម្បទាននេះ ក្រុមហ៊ុន SCA ត្រូវបានតម្រូវឱ្យអនុវត្តការវិនិយោគបន្ថែមក្នុងរយៈពេល៤-៥ឆ្នាំនេះ។ គម្រោងនេះ ត្រូវបានប៉ាន់ប្រមាណថាត្រូវចំណាយថវិកាប្រមាណ ៧២លាន ដុល្លាសហរដ្ឋអាមេរិក ដែលក្នុងនោះរួមមាន ៖ (១) ការផ្តល់ហិរញ្ញប្បទានគាំទ្រសម្រាប់កម្មវិធីចំណាយមូលធន ២០០៣-២០០៧ ដែលត្រូវចំណាយថវិកាសរុបចំនួន ៤៧,១ លានដុល្លាសហរដ្ឋអាមេរិក រាប់បញ្ចូល ២៣,២ លានដុល្លា សហរដ្ឋអាមេរិក ដើម្បីកែលម្អសម្ភារៈបរិក្ខារបស់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ (ការធ្វើឱ្យផ្លូវ runway ឱ្យបានកាន់តែឆ្ងាយ និង ធំជាងមុន ការពង្រីកផ្លូវ taxiway ការពង្រីកផ្លូវ aprons និងសម្ភារៈបរិក្ខានៅក្នុងឃ្លាំង ព្រមទាំង ការធ្វើទំនើបកម្មទៅលើឧបករណ៍ប្រតិបត្តិការរបស់អាកាសយានដ្ឋាន) និង ២៣,៩ លានដុល្លាសហរដ្ឋអាមេរិក សម្រាប់អាកាសយានដ្ឋានអន្តរជាតិសៀមរាប-អង្គរ (ការជួសជុលចម្បងៗទៅលើផ្លូវ runway និង ផ្លូវ taxiway ការពង្រីកផ្លូវ taxiway និង ផ្លូវ aprons ការពង្រីកស្ថានីយ៍អ្នកដំណើរ ការធ្វើទំនើបកម្មទៅលើឧបករណ៍ប្រតិបត្តិការនៅក្នុងអាកាសយានដ្ឋាន និង ការសាងសង់ឃ្លាំងទំនិញថ្មីមួយ) (២) ការផ្តល់ហិរញ្ញប្បទានចំនួន ៨,២ លានដុល្លា សហរដ្ឋអាមេរិក ដែលជំពាក់អ្នកម៉ៅការសាងសង់សម្រាប់ចំណាយមូលធនកន្លងមក និង (៣) ការផ្តល់ហិរញ្ញប្បទានឡើងវិញ ក្នុងចំនួនទឹកប្រាក់ ១៦,៧ លានដុល្លាសហរដ្ឋអាមេរិក នៃកម្ចីដែលមានស្រាប់របស់ម្ចាស់ភាគហ៊ុន និងកម្ចី ស្ពានពាណិជ្ជកម្មមួយ។ ការវិនិយោគរបស់ IFC រួមមានកម្ចីរហូតដល់ ១០លានដុល្លាសហរដ្ឋអាមេរិក។ កម្ចីដែលបាន ផ្តល់ជូនទៅឱ្យក្រុមហ៊ុន SCA ត្រូវបានដកសាច់ប្រាក់ និងប្រើប្រាស់យ៉ាងពេញលេញ ហើយបច្ចុប្បន្នគម្រោងនេះ កំពុងស្ថិតក្នុងដំណាក់កាលត្រួតពិនិត្យ។

### ២.២. ពាក្យបណ្តឹង

ក្នុងខែមិថុនា ឆ្នាំ២០១៣ មានគ្រួសារចំនួន៥៩ មកពីភូមិថ្មគោល និងភូមិព្រៃជីសាក់ បានដាក់ពាក្យបណ្តឹងមួយទៅកាន់ការិយាល័យ CAO ដោយមានកិច្ចគាំទ្រ និងជំនួយពីអង្គការមិនមែនរដ្ឋាភិបាលមួយនៅក្នុងប្រទេសកម្ពុជា ដែលមានឈ្មោះថាអង្គការសមធម៌កម្ពុជា។ ពាក្យបណ្តឹងនេះ បានលើកឡើងនូវបញ្ហាកង្វល់មួយចំនួនអំពីការគំរាមកំហែងយកដី និង លទ្ធភាពដែលអាចនាំឱ្យមានការបង្ខំ

បណ្តេញប្រជាជនចេញ ទាក់ទងទៅនឹងការអភិវឌ្ឍន៍អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ បញ្ហាជុំវិញការពិគ្រោះយោបល់ជាមួយសហគមន៍ និងដំណើរការសមស្រប ក៏ត្រូវបានលើកឡើងផងដែរ នៅក្នុងពាក្យបណ្តឹង។ ដើមបណ្តឹងបានស្នើសុំឱ្យការិយាល័យ CAO រក្សាអត្តសញ្ញាណរបស់ពួកគេជាការសម្ងាត់។

សមាជិកសហគមន៍បានថ្លែងឱ្យដឹងថា ពួកគេបានទទួលសេចក្តីជូនដំណឹងឱ្យពួកគេរើចេញពីកន្លែងដែលពួកគេកំពុងរស់នៅ ពីអាជ្ញាធរខណ្ឌពោធិ៍សែនជ័យ[៣] យ៉ាងណាមិញ មិនទាន់មានការបណ្តេញចេញណាមួយដែលបានកើតឡើងនៅឡើយទេ។ យោងតាមអ្នកពាក់ព័ន្ធ និងសារព័ត៌មាន[៤] ដែលដើមបណ្តឹងបានផ្តល់ជូននៅថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១៣ បាតុករបានធ្វើការតវ៉ានៅមុខអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ដោយបានធ្វើការបិទច្រកចូលជាបណ្តោះអាសន្ន ហើយទីបំផុត ពួកគេត្រូវបានបំបែកដោយកងកម្លាំងនគរបាល។ ក្រុមហ៊ុន SCA បានពោលអះអាងថា ការតាំងទីលំនៅមួយចំនួនស្ថិតនៅក្នុង "តំបន់សុវត្ថិភាព" របស់អាកាសយានដ្ឋាន ដែលចំណុចនេះបង្កការរំលោភបំពានជាសក្តានុពលទៅលើបទបញ្ញាផ្នែកសន្តិសុខ និងសុវត្ថិភាព របស់អាកាសយានដ្ឋានអន្តរជាតិ និងបង្កឱ្យមាននូវហានិភ័យជាសក្តានុពលចំពោះអ្នកដំណើរ ព្រមទាំងគ្រួសារខ្លួនឯងផ្ទាល់។ ទីស្តីការគណៈរដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបង្កើតគណៈកម្មាធិការដីធ្លីមួយ ដែលធ្វើការងារជាមួយក្រុមហ៊ុន SCA ដើម្បីប៉ាន់ប្រមាណទៅលើការប្រតិបត្តិតាមបទដ្ឋានរបស់អង្គការអាកាសចរណ៍ស៊ីវិលអន្តរជាតិ (ICAO) និង ប៉ាន់ប្រមាណទៅលើសេចក្តីត្រូវការចំពោះលទ្ធភាពនៃការតាំងទីលំនៅថ្មី។ ដើមបណ្តឹងបានប្រាប់ CAO ថាពួកគេបានដាក់ពាក្យបណ្តឹង ដោយសារតែកិច្ចខិតខំរបស់ពួកគេ ដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ និង ដើម្បីស្វែងរកការដោះស្រាយចំពោះបញ្ហារបស់ពួកគេនៅក្នុងប្រទេសពុំទទួលបានជោគជ័យ។

---

[៣] ដើមបណ្តឹងបានដកស្រង់សេចក្តីជូនដំណឹងឱ្យរើទីលំនៅ លេខ០៧៨ សជណ ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១២ និង លិខិតជូនដំណឹងឱ្យរើទីលំនៅបន្ថែមទៀតពីអភិបាលខណ្ឌពោធិ៍សែនជ័យ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១២។

[៤] សូមមើលសារព័ត៌មានខេមបូឌាដេលី ដែលមានចំណងជើងថា *Eviction Protesters Block Phnom Penh International Airport*, by Aun Pheap, 23 May 2013, http://www.cambodiadaily.com/archive/eviction-protesters-block-phnom-penh-international-airport-26147/

## ៣. សង្ខេបការប៉ាន់ប្រមាណ

គោលបំណងនៃការប៉ាន់ប្រមាណរបស់ការិយាល័យ CAO នេះ គឺដើម្បីបញ្ជាក់អំពីបញ្ហា និងការព្រួយបារម្ភនានា ដែលដើមបណ្តឹងបានលើកឡើង ដើម្បីប្រមូលព័ត៌មានអំពីរបៀបដែលអ្នកពាក់ព័ន្ធដទៃទៀត យល់ឃើញចំពោះស្ថានភាពនេះ ដើម្បីកំណត់ថាតើដើមបណ្តឹង និងក្រុមហ៊ុន SCA មានបំណងចង់បន្តដំណើរការដោះស្រាយវិវាទ ក្រោមកិច្ចគាំទ្រពីយន្តការដោះស្រាយវិវាទរបស់ការិយាល័យ CAO ឬ ពាក្យបណ្តឹងគួរផ្ទេរទៅផ្នែកប្រតិបត្តិរបស់ការិយាល័យ CAO ដើម្បីធ្វើការវាយតម្លៃ។ ការិយាល័យ CAO មិនប្រមូលព័ត៌មានដើម្បីធ្វើការវិនិច្ឆ័យលើអង្គសេចក្តីនៃពាក្យបណ្តឹង ក្នុងអំឡុងពេលដែលការិយាល័យនេះ កំពុងធ្វើការប៉ាន់ប្រមាណឡើយ។

### ៣.១ វិធីសាស្ត្រ

ការប៉ាន់ប្រមាណរបស់ការិយាល័យ CAO ទៅលើពាក្យបណ្តឹង រួមមាន ៖

- ការពិនិត្យឡើងវិញទៅលើឯកសារគម្រោង ព្រមទាំងកម្រងឯកសារដែលគាំទ្រដល់ពាក្យបណ្តឹង ដែលដើមបណ្តឹង និងអង្គការសមធម៌កម្ពុជា (EC) បានដាក់ជូន។
- ការរៀបចំកិច្ចប្រជុំជាមួយដើមបណ្តឹង អង្គការសមធម៌កម្ពុជា ក្រុមការងារគម្រោងរបស់ IFC ក្រុមហ៊ុន SCA និងគណៈកម្មាធិការដីធ្លី (LC) នៃទីស្តីការគណៈរដ្ឋមន្ត្រី និង
- ដំណើរទស្សនៈកិច្ចទៅកាន់ភូមិដែលទទួលរងផលប៉ះពាល់ជាសក្តានុពល។

### ៣.២. ការរកឃើញ

#### ៣.២.១. សង្ខេបបញ្ហា

ផ្នែកនេះសង្ខេបអំពីបញ្ហាដែលក្រុមអ្នកពាក់ព័ន្ធផ្សេងៗគ្នាបានលើកឡើង ប៉ុន្តែផ្នែកនេះ ពុំមានការវិនិច្ឆ័យពីការិយាល័យ CAO ចំពោះអង្គសេចក្តីនៃពាក្យបណ្តឹងឡើយ។

ផ្អែកលើពាក្យបណ្តឹងដើម និង កិច្ចពិភាក្សាជាមួយអ្នកពាក់ព័ន្ធជាបន្តបន្ទាប់ ដែលជាផ្នែកមួយនៃការប៉ាន់ប្រមាណរបស់ការិយាល័យ CAO បញ្ហាចម្បងៗចាំបាច់ដែលត្រូវលើកយកមកធ្វើការដោះស្រាយចំពោះពាក្យបណ្តឹងនេះ រួមមាន ៖

១. តើប្រជាពលរដ្ឋមូលដ្ឋាននៅភូមិថ្មគោល ភូមិព្រៃជីសីកា និងភូមិគោកចំបក់[៥] អាចចូលរួមជាមួយក្រុមហ៊ុន SCA និងអាជ្ញាធររដ្ឋាភិបាលពាក់ព័ន្ធ ដើម្បីកំណត់ទៅលើផលប៉ះពាល់ចំពោះប្រជាពលរដ្ឋ និងទ្រព្យសម្បត្តិរបស់ពួកគេ ដែលកើតឡើងដោយសារតែការកែលម្អទៅលើមូលដ្ឋានអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង/ ឬ ការកែលម្អសន្តិសុខ បានដោយរបៀបណា?
២. តើគេអាចពិចារណាយ៉ាងដូចម្តេចទៅលើការរៀបចំដោយឡែកដែលអាចធ្វើទៅបាន ដើម្បីជៀសវាងការជម្លៀសរូបវ័ន្ត? ក្នុងករណីចាំបាច់ តើសំណង និង/ឬ ការតាំងទីលំនៅថ្មីរបស់ប្រជាពលរដ្ឋដែលទទួលរងផលប៉ះពាល់ នឹងត្រូវបានគ្រប់គ្រង និង អនុវត្តដោយរបៀបណា?
៣. តើអ្នកពាក់ព័ន្ធអាចធ្វើការងារជាមួយគ្នា ដើម្បីដោះស្រាយការព្រួយបារម្ភលើផ្នែកសុវត្ថិភាព និង សន្តិសុខ សម្រាប់អាកាសយានដ្ឋាន និងប្រជាពលរដ្ឋដែលរស់នៅក្បែររបងអាកាសយានដ្ឋាន បានដោយរបៀបណា?

### ៣.២.២. សង្ខេបអំពីគោលដៅ និងប្រយោជន៍របស់អ្នកពាក់ព័ន្ធ

ផ្អែកលើការពិភាក្សាជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដូចមានរៀបរាប់ខាងលើ ក្រុមការងាររបស់ការិយាល័យ CAO បានស្តាប់លឺ និងយល់អំពីគោលដៅ និងប្រយោជន៍រួមសំខាន់ៗដូចខាងក្រោម ៖

- ការដោះស្រាយបញ្ហាពាក្យបណ្តឹងក្នុងលក្ខណៈបែបសហការ និងប្រកបដោយសន្តិភាព
- ការរៀនសូត្រពីបទពិសោធន៍របស់អាកាសយានដ្ឋានខេត្តព្រះសីហនុ ទាក់ទងទៅនឹងការតាំងទីលំនៅថ្មី និង សំណងសម្រាប់ប្រជាពលរដ្ឋក្នុងមូលដ្ឋានដែលទទួលរងផលប៉ះពាល់ និងការយកមេរៀនដែលពាក់ព័ន្ធមក អនុវត្តនៅក្នុងរាជធានីភ្នំពេញ
- បន្តជូនដំណឹងដល់អ្នកពាក់ព័ន្ធទាំងអស់ឱ្យបានជ្រាបអំពីផែនការពង្រីក និង កែលម្អអាកាសយានដ្ឋាន។

នៅក្នុងជំនួបជាមួយដើមបណ្តឹង និង ប្រជាពលរដ្ឋដែលអាចទទួលរងផលប៉ះពាល់ជាសក្តានុពល ការិយាល័យ CAO បានធ្វើការកត់សម្គាល់ទៅលើបញ្ហាផលប្រយោជន៍ និង ការព្រួយបារម្ភមួយចំនួនបន្ថែមទៀត ដែលពួកគេបានស្តែងឱ្យដឹង ៖

[៥] បើទោះបីជាពុំមានពាក្យបណ្តឹងផ្លូវការពីភូមិគោកចំបក់ក៏ដោយ ប៉ុន្តែ ពាក្យបណ្តឹងដែលបានដាក់ទៅការិយាល័យ CAO បានលើកឡើងនូវការព្រួយបារម្ភថា គ្រួសារដែលរស់នៅក្នុងភូមិនោះ ក៏អាចទទួលរងផលប៉ះពាល់ផងដែរ។

- ជៀសវាងការតាំងទីលំនៅថ្មីឱ្យបានច្រើនបំផុតដូចដែលអាចធ្វើទៅបាន
- រៀបចំឱ្យមានដំណើរការផ្តល់សំណងមួយដែលមានភាពយុត្តិធម៌ និងមានតម្លាភាព ប្រសិនបើពុំមានជម្រើសដោយឡែកដទៃទៀតដែលអាចធ្វើទៅបាន ក្រៅពីការតាំងទីលំនៅឡើងវិញ
- ការធានាឱ្យមានប្លង់ដីស្របច្បាប់
- ការទទួលបានព័ត៌មានអំពីទិដ្ឋភាពនៃគម្រោងអាកាសយានដ្ឋាន ដែលប៉ះពាល់ដល់ពួកគេ
- ការមានសម្លេង និង ឥទ្ធិពលនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត ដែលបង្កឱ្យមានផលប៉ះពាល់ទៅលើពួកគេ ទាក់ទងទៅនឹងអាកាសយានដ្ឋាន និងលទ្ធភាពនៃការតាំងទីលំនៅឡើងវិញ
- ការរៀបចំឱ្យមាននូវកិច្ចសន្ទនាបែបស្ថាបនានៅក្នុងបរិយាកាសមួយប្រកបដោយសុវត្ថិភាព ដោយពុំមានការភ័យខ្លាចចំពោះការសងសឹក។

## ៤. ជំហានបន្ទាប់

ដើមបណ្តឹងក្រុមហ៊ុន SCA និង គណៈកម្មាធិការដីធ្លី បានឯកភាពធ្វើការងារជាមួយក្រុមការងារដោះស្រាយវិវាទនៃការិយាល័យ CAO ដើម្បីខិតខំដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង ដោយប្រើប្រាស់ដំណោះស្រាយបែបសហការ។ ក្នុងអំឡុងពេលនៃដំណើរការដោះស្រាយវិវាទរបស់ការិយាល័យ CAO ការិយាល័យនេះ ផ្តល់នូវការសម្រុះសម្រួល/ការសម្របសម្រួលបែបអព្យាក្រឹត្យ និង រៀបចំឱ្យមាននូវកិច្ចប្រជុំដោយឡែក និងកិច្ចប្រជុំរួមទៅតាមភាពចាំបាច់។ ការិយាល័យ CAO នឹងធ្វើការងារជាមួយភាគីនានា ដើម្បីជួយដល់ពួកគេ ឱ្យមានការឯកភាពទៅលើពេលវេលា ដំណើរការ និងកាលវិភាគសម្រាប់កិច្ចប្រជុំ។

## ឧបសម្ព័ន្ធ ក. ដំណើរការដោះស្រាយពាក្យបណ្តឹងរបស់ការិយាល័យ CAO

ការិយាល័យប្រតិបត្តិ ទីប្រឹក្សា អ្នកដោះស្រាយវិវាទ (ការិយាល័យCAO) គឺជាយន្តការគណនេយ្យភាព និងឧបាស្រ័យឯករាជ្យ សម្រាប់សារជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) និងទីភ្នាក់ងារធានាការវិនិយោគពហុភាគី (MIGA) ដែលជាសាខាផ្នែកវិស័យឯកជនរបស់ក្រុមធនាគារពិភពលោក។ ការិយាល័យ CAO រាយការណ៍ដោយផ្ទាល់ជូនដល់ប្រធានក្រុមធនាគារពិភពលោក ហើយការិយាល័យនេះ មានអាណត្តិការងារក្នុងការជួយដោះស្រាយពាក្យបណ្តឹងពីប្រជាពលរដ្ឋ ដែលទទួលរងផលប៉ះពាល់ពីគម្រោងដែលមានការគាំទ្រពី IFC/MIGA ក្នុងលក្ខណៈមួយប្រកបដោយភាពយុត្តិធម៌ មិនលំអៀង និងប្រកបដោយភាពស្ថាបនា សំដៅលើកកម្ពស់លទ្ធផល ផ្នែកសង្គម និងបរិស្ថាននៃគម្រោងទាំងនោះ។

ការប៉ាន់ប្រមាណរបស់ការិយាល័យ CAO ត្រូវបានធ្វើឡើងដោយមុខងារផ្នែកដោះស្រាយវិវាទរបស់ការិយាល័យ CAO។ គោលបំណងនៃការប៉ាន់ប្រមាណរបស់ការិយាល័យ CAO គឺដើម្បី ៖ (១) បញ្ជាក់អំពីបញ្ហា និង ការព្រួយបារម្ភនានា ដែលដើមបណ្តឹងបានលើកឡើង (២) ប្រមូលព័ត៌មានអំពីរបៀបដែលអ្នកពាក់ព័ន្ធដទៃទៀតយល់ឃើញចំពោះស្ថានភាពនេះ និង (៣) ដើម្បីជួយដល់ផ្នែកដោះស្រាយវិវាទរបស់ការិយាល័យ CAO និងអ្នកពាក់ព័ន្ធនានា ធ្វើការកំណត់ ថាតើពួកគេអាចដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹងបានដែរឬទេ និង ដោយរបៀបណា។

ឯកសារនេះ គឺជារបាយការណ៍បឋមមួយអំពីទស្សនៈដែលក្រុមការងាររបស់ការិយាល័យ CAO បានស្តាប់លឺ និង ការពន្យល់អំពីជំហានបន្ទាប់។ *របាយការណ៍នេះ មិនធ្វើការវិនិច្ឆ័យណាមួយទៅលើអង្គសេចក្តីនៃពាក្យបណ្តឹងឡើយ។*

យោងតាមគោលការណ៍ណែនាំប្រតិបត្តិរបស់ការិយាល័យ[៦] CAO ជំហានខាងក្រោមត្រូវបានអនុវត្តតាម ដើម្បីឆ្លើយតបទៅនឹងពាក្យបណ្តឹងដែលបានទទួល ៖

ជំហានទី១ ៖ **ការបញ្ជាក់ថាបាន ទទួលពាក្យបណ្តឹង**

ជំហានទី២ ៖ **ការបំពេញល័ក្ខខ័ណ្ឌបណ្តឹង៖** ការកំណត់ទៅលើការបំពេញល័ក្ខខ័ណ្ឌរបស់ពាក្យបណ្តឹង សម្រាប់ការប៉ាន់ប្រមាណក្រោមអាណត្តិការងាររបស់ការិយាល័យ CAO (មិនលើសពី ១៥ថ្ងៃនៃថ្ងៃធ្វើការ)

[៦] សម្រាប់ព័ត៌មានលម្អិតអំពីតួនាទី និងការងាររបស់ការិយាល័យ CAO សូមមើលគោលការណ៍ណែនាំប្រតិបត្តិទាំងស្រុង ៖ http://www.cao-ombudsman.org/about/whoweare/index.html

ជំហានទី៣ ៖ **ការប៉ាន់ប្រមាណដោយផ្នែកដោះស្រាយវិវាទ ៖** ការប៉ាន់ប្រមាណទៅលើបញ្ហា និង ផ្តល់កិច្ចគាំទ្រ ជូនដល់អ្នកពាក់ព័ន្ធ ដើម្បីឱ្យយល់ និង កំណត់ថាតើដំណោះស្រាយមួយបែបសហការអាចធ្វើទៅ បានដែរឬទេ តាមរយៈដំណើរការមួយដែលមានការសម្របសម្រួលពីផ្នែកដោះស្រាយវិវាទរបស់ការិយាល័យ CAO ឬ ថាតើករណីនេះ គួរផ្ទេរទៅផ្នែកប្រតិបត្តិរបស់ការិយាល័យ CAO ដើម្បីធ្វើការវាយតម្លៃទៅលើការអនុវត្តន៍ការងារផ្នែកសង្គម និង បរិស្ថានរបស់ IFC/ MIGA។ ការប៉ាន់ប្រមាណអាចមានរយៈពេលអតិបរមាចំនួន ១២០ថ្ងៃ នៃថ្ងៃធ្វើការ។

ជំហានទី៤ ៖ **ការសម្របសម្រួលសម្រាប់ការតាំងទីលំនៅ ៖** ប្រសិនបើដំណើរការរបស់ផ្នែកដោះស្រាយវិវាទនៃការិយាល័យ CAO នៅតែបន្ត ដំណាក់កាលនេះ ពាក់ព័ន្ធទៅនឹងការផ្តួចផ្តើមដំណើរការដោះស្រាយ វិវាទមួយ (ជាទូទៅមានមូលដ្ឋានផ្អែកលើ ឬ ផ្តួចផ្តើមដោយអនុស្សរណៈនៃការយោគយល់ និង/ឬ វិធានមូលដ្ឋាន ដែលមានការឯកភាពពីភាគីពាក់ព័ន្ធ) តាមរយៈការសម្របសម្រួល/ការសម្រុះសម្រួល ការស្វែងរកការពិតរួមគ្នា ឬ ដំណើរការដោះស្រាយដទៃទៀតដែលមានការឯកភាពគ្នា ដែលនាំឱ្យឈានទៅរកការព្រមព្រៀងមួយទៅលើការតាំងទីលំនៅ ឬ គោលដៅសមស្របដទៃទៀត ដែលមានការឯកភាពគ្នា។ គោលបំណងចម្បងនៃវិធីសាស្រ្តដោះស្រាយបញ្ហា គឺត្រូវដោះស្រាយបញ្ហាដែលបានលើកឡើងនៅក្នុងពាក្យបណ្តឹង និង បញ្ហាគួរឱ្យកត់សម្គាល់ដទៃទៀតពាក់ព័ន្ធទៅនឹងពាក្យបណ្តឹង ដែលត្រូវបានកំណត់ក្នុងអំឡុងពេលនៃដំណើរការប៉ាន់ប្រមាណ ឬ ដំណើរការដោះស្រាយបញ្ហា ក្នុងលក្ខណៈមួយដែលអាចទទួលយកបានដោយភាគីដែលទទួលរងផលប៉ះពាល់ [៧]។

ឬ

[៧] ក្នុងករណីដែលអ្នកពាក់ព័ន្ធមិនអាចដោះស្រាយបញ្ហាតាមរយៈដំណើរការបែបសហការ នៅក្នុងក្របខ័ណ្ឌពេលវេលាដែលបានឯកភាពគ្នា ជាដំបូង ផ្នែកដោះស្រាយវិវាទនៃការិយាល័យ CAO នឹងពិនិត្យមើលលទ្ធភាពក្នុងការជួយដល់អ្នកពាក់ព័ន្ធក្នុងការទម្លាយភាពជាប់គាំងនេះ។ ប្រសិនបើ សកម្មភាពនេះមិនអាចធ្វើទៅបាន ការិយាល័យ CAO នឹងជូនដំណឹងដល់អ្នកពាក់ព័ន្ធ រាប់បញ្ចូលទាំងបុគ្គលិក IFC/MIGA ប្រធាន និង ក្រុមប្រឹក្សាភិបាលនៃក្រុមធនាគារពិភពលោក និងសាធារណជនថា ផ្នែកដោះស្រាយវិវាទនៃការិយាល័យ CAO បានបញ្ចប់ការចូលរួមរបស់ខ្លួន នៅក្នុងពាក្យបណ្តឹងនេះ ហើយពាក្យបណ្តឹងនេះកំពុងត្រូវបានផ្ទេរទៅឱ្យផ្នែកត្រួតពិនិត្យភាពអនុលោមនៃការិយាល័យ CAO ដើម្បីធ្វើការ វាយតម្លៃ។

**ការវាយតម្លៃ/សវនកម្មទៅលើការប្រតិបត្តិតាម ៖** ប្រសិនបើដំណោះស្រាយបែបចូលរួមមួយមិនអាចធ្វើទៅបាន ផ្នែកប្រតិបត្តិនៃការិយាល័យ CAO នឹងផ្តួចផ្តើមឱ្យមានការវាយតម្លៃមួយទៅលើការយកចិត្តទុកដាក់ផ្នែកសង្គម និងបរិស្ថានរបស់ IFC/MIGA ចំពោះគម្រោងដែលជាកម្មវត្ថុនៃបណ្តឹង ដើម្បីកំណត់ថាតើការធ្វើសវនកម្មលើការប្រតិបត្តិមួយនៃភាពពាក់ព័ន្ធរបស់ IFC/MIGA នៅក្នុងគម្រោង មានតម្លៃសក្តិសមនឹងធ្វើដែរឬទេ។

ជំហានទី៥ ៖ **ការត្រួតពិនិត្យ** និងការតាមដាន

ជំហានទី៦ ៖ **សេចក្តីសន្និដ្ឋាន**/ការបិទករណី